ROLLS-ROYCE | សេចក្តីប្រកាសព័ត៌មាន

Rolls-Royce ប្រកាសថា ម៉ូដែល Black Badge Ghost ជា សែស្រឡាយ Black Badge បរិសុទ្ធបំផុត

**ថ្ងៃទី 2៨ តុលា 2021 ក្រុង Goodwood, West Sussex**

- រថយន្ត Black Badge Ghost បង្ហាញខ្លួនជាលើកដំបូងសម្រាប់ការរចនាម៉ូដបែប Post Opulent បែបក្រម៉ៅ
- ម៉ាស៊ីន 6.75-លីត្រ V12 នៅពេលនេះ បង្កើនកម្លាំងថាមពល (600PS/592hp) និងរង្វិលជុំម៉ាស៊ីន (900NM)
- ប្រព័ន្ធចលករ (drivetrain) និងសាក់ស៊ី ត្រូវបានកែច្នៃឡើងវិញ ដើម្បីឲ្យដំណើរការកាន់តែមានសន្ទុះជាងមុន
- រថយន្តជាសមុច្ច័យបានបង្ហាញជាលើកដំបូង នូវស្បែក Turchese ដ៏ស្រស់ស្អាតទាក់ភ្នែក និង បន្ទះស្រោបជាកាបោន (Technical carbon)
- យ៉ាន់កង់អាលុយមីញ៉ូមបែប Bespke ដែលបានបង្ហាញនៅក្នុងសែស្រឡាយ Black Badge ដោយមានផ្សំជាមួយនឹងកាបោនផងដែរ
- រូបសញ្ញាអានន្ត នៅតែបន្តធ្វើជាកូដសម្គាល់វិនាដកម្មរបស់រថយន្ត Rolls-Royce

អគ្គនាយកក្រុមហ៊ុនរថយន្ត Rolls-Royce លោក Torsten Müller-Ötvös មានប្រសាសន៍ថា៖

"ក្រោយពេលមានការពិភាក្សាផ្ទៃក្នុងយ៉ាងល្អិតល្អន់ ក្រុមហ៊ុន *Rolls-Royce* បានប្រកាសថា ខ្លួននឹងធ្វើការឆ្លើយតបជាផ្លូវការចំពោះអតិថិជនប្រភេទថ្មី៖ គឺការបង្កើតរថយន្តបែប *Bespoke* ជាអចិន្ត្រៃយ៍សម្រាប់រថយន្តរបស់ខ្លួនក្នុងសែស្រឡាយ *Black Badge* ។ ផលិតផលរថយន្តទាំងអស់នេះ បានសម្ពោធនៅឆ្នាំ *2016* ជារថយន្តដែលមានសោភ័ណភាពបែបក្រម៉ៅ មានចរិតបែបបន្ទាន់ ហើយបំពាក់បរិក្ខាបែបវិនាដកម្ម ។

"ក្នុងរយៈកាលប្រាំឆ្នាំ ចាប់តាំងពី សែស្រឡាយ *Black Badge* បានដាក់លក់ជាសាធារណៈមក រថយន្តនេះ បានក្លាយជានិមិត្តរូបនៃផលិតផលកំពូលប្រណីតប្រភេទថ្មី ដោយបានជួយជំរុញឧស្សាហកម្មប្រណីតថែមទៀតផង។ ដោយហេតុនេះហើយ សឹងតែគ្រប់ក្រុមហ៊ុនផលិតផលប្រណីត បានផលិតនូវផលិតផលរបស់ខ្លួន ដោយបានច្បាមយកស្មារតីបែបក្រម៉ៅងងឹតរបស់ *Black Badge* នេះ។



The Drive, Westhampnett, Chichester, PO18 0SH, UK +44 (0)1243 384000 enquiries@rolls-roycemotorcars.com www.rolls-roycemotorcars.com

Rolls-Royce Motor Cars Limited. Registered in England and Wales. Company number 3522604. Registered address: Summit ONE, Summit Avenue, Farnborough, Hampshire, GU14 0FB.
Rolls-Royce Motor Cars Ltd is authorised and regulated by the Financial Conduct Authority in relation to its credit broking activities in the UK

“នៅថ្ងៃនេះ យើងសូមប្រកាសផលិតផលមួយដែលតំណាងឲ្យរថយន្ត *Black Badge* ប្រភេទថ្មី ជារថយន្តដែល មានការរចនាបទបែប *minimalism* និង *Post Opulent* ដែលជាការរៀបរាប់ឡើងវិញពីតំណាលរឿងរបស់ *Ghost* ប៉ុន្តែសង្កត់ធ្ងន់លើ ការប្រើប្រាស់ពណ៌ខ្មៅ ។ រថយន្តដែលទំនើបជាងគេបំផុតរបស់យើងនេះ ត្រូវបានច្នៃបង្កើតឡើងវិញ ដើម្បីសម្គាល់បុគ្គលិកលក្ខណៈមួយបែបទៀតខុសពី *Rolls-Royce* ធម្មតា ពោលគឺ៖ មានភាពច្បាស់លាស់ មានថាមពល និងមានអំណាច ។ នេះជារថយន្តសៃស្រឡាយ *Black Badge* ដ៏បរិសុទ្ធបំផុតនៅក្នុងប្រវត្តិកាលរបស់ម៉ាកយីហោ *Rolls-Royce* ។ នេះគឺរថយន្ត *Black Badge Ghost”* ។

## សេចក្តីផ្តើម

ក្រុមហ៊ុនរថយន្ត Rolls-Royce មានការយល់ដឹងយ៉ាងច្បាស់លាស់អំពីអតិថិជនរបស់ខ្លួន។ ទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងសុភាពបុរស និងសុភាពនារីនានា ដែលគាំទ្រម៉ាកយីហោរបស់យើង ជួយឲ្យអ្នកធ្វើសេចក្តីសម្រេចចិត្តនៅក្នុងក្រុមហ៊ុន មានការយល់ដឹងឥតប្រៀបបានទាក់ទងនឹងអ្នកប្រើប្រាស់ទំនិញកំពូលប្រណីត ដូចជា៖ ចំណង់ចំណូលចិត្តផ្នែកសោភ័ណភាព លក្ខខណ្ឌសម្រាប់របៀបរបបក្នុងជីវិតដែលត្រូវធ្វើឲ្យល្អឥតខ្ចោះ និងលំអាននៃការផ្លាស់ប្តូររសជាតិជាដើម។ តាមរយៈការយល់ដឹងនេះហើយ ក៏ដូចជារបាយការណ៍សង្ខេបដែលផ្តល់ដោយអង្គភាពព័ត៌មានពិភពប្រណីត របស់ក្រុមហ៊ុនយើង បានធ្វើឲ្យយើងអាចបង្កើតផលិតផលដែលត្រឹមត្រូវ ។ ហើយសៃស្រឡាយរថយន្ត Black Badge គឺជាតឹកតាងយ៉ាងច្បាស់ក្រឡែត។

ក្រុមហ៊ុនរថយន្ត Rolls-Royce តែងតែបានទាក់ភ្នែកអតិថិជនដែលចូលចិត្តបដិវដ្តន៍ ជាសុភាពបុរស និងសុភាពនារី ដែលក្រោកឈរ ហើយកសាងជោគជ័យរបស់ខ្លួន ដោយពុំខ្វល់ពីវិន័យ ហ៊ានប្រថុយ និងប្រឆាំងនឹងអ្វីដែលងាយៗ ។ នៅក្នុងទសវត្សឆ្នាំ 2020 សុភាពបុរស និងសុភាពនារីទាំងនេះ បញ្ជាទិញផលិតផលប្រណីតទៅតាមលក្ខខណ្ឌរបស់ខ្លួន។ ពួកគេបដិសេធមិនប្រើសម្លៀកបំពាក់ឈុតសម្រាប់ការធ្វើដំណើរតាមដងផ្លូវ គេប្រើរូបិយវត្ថុរបស់ Blockchain មិនប្រើធនាគារ ហើយមានឥទ្ធពលលើពិភពខាងក្រៅតាមរយៈការប្រើប្រាស់ប្រព័ន្ធឌីជីថលរបស់ពួកគេ។ ធ្វើដូច្នេះ ពួកគេបានបង្កើតនូវលេខកូដថ្មីនៃពាក្យថាប្រណីតភាព ដែលស្របទៅតាមការយល់ឃើញរបស់ខ្លួន៖ គឺការរចនាដែលមានសោភ័ណភាពខ្មៅងងឹតជាងមុន មានចរិតច្បាស់លាស់ និងហំហាន ។

ការបញ្ជាទិញរថយន្ត Rolls-Royce របស់ពួកគេ មិនមានភាពខុសប្លែកគ្នានោះទេ ។ ដូច្នេះ ម៉ាកយីហោរបស់យើងបានឆ្លើយតបទៅតាមតម្រូវការរបស់ពួកគេ ដោយបានបង្កើតនូវសំណុំពណ៌ថ្មីៗ ការតុបតែងផ្នែកបច្ចេកទេសកាន់តែសម្បូរបែបជាងមុន  និងថាមពលក្នុងការបើកបរខ្លាំងជាងមុន ដោយនៅតែគិតគូរយ៉ាងល្អិតល្អន់លើសមត្ថភាពនៃការបើកបរដោយមិនបាច់ប្រឹង ដែលចំណុចនេះហើយបានទាក់ទាញអតិថិជនក្រុមនេះឲ្យងាកមកប្រើប្រាស់ម៉ាកយីហោ Rolls-Royce ។

បច្ចុប្បន្ន ការកុម្ម៉ង់រថយន្ត Black Badge ជាសៃស្រឡាយផ្សេងមួយទៀតរបស់ Rolls-Royce ដែលទទួលបានជោគជ័យខ្លាំងស្មើនឹងជាង 27% នៃការកុម្ម៉ង់ជុំវិញពិភពលោក ហើយរថយន្តនេះ មានកូដសម្គាល់ដោយសញ្ញាគណិតវិទ្យា ដែលតំណាងឲ្យអា



The Drive, Westhampnett, Chichester, PO18 0SH, UK   +44 (0)1243 384000   enquiries@rolls-roycemotorcars.com   www.rolls-roycemotorcars.com

Rolls-Royce Motor Cars Limited. Registered in England and Wales. Company number 3522604. Registered address: Summit ONE, Summit Avenue, Farnborough, Hampshire, GU14 0FB.
Rolls-Royce Motor Cars Ltd is authorised and regulated by the Financial Conduct Authority in relation to its credit broking activities in the UK

នន្ត ដែលសញ្ញានេះស្ថិតនៅផ្នែកខាងក្នុងរថយន្ត ។ រូបសញ្ញានេះ ធ្លាប់ទៅបានយកទៅប្រើនៅលើទូកខ្យល់ Blue Bird K3 របស់ Sir Malcolm Campbell ដែលទូកខ្យល់នេះដើរដោយម៉ាស៊ីន Rolls-Royce ហើយបានបំបែកឯតទគ្គកម្មថែមទៀតផង ។ ដូច្នេះហើយ បានជាអ្នករចនាម៉ូតរបស់ក្រុមហ៊ុនយើង ប្រើប្រាស់សញ្ញានេះ សម្រាប់រថយន្តសែស្រឡាយ Black Badge ដើម្បីឆ្លុះបញ្ចាំងឲ្យឃើញពីការខិតខំឥតស្រាកស្រាន ធ្វើឲ្យមានថាមពលខ្លាំង ។

ក្រុមហ៊ុនរថយន្ត Rolls-Royce បានបញ្ចេញរថយន្ត Black Badge លើកដំបូង ជាមួយនឹងម៉ូដែល Wraith និង Ghost នៅឆ្នាំ 2016 និងម៉ូដែល Dawn នៅឆ្នាំ 2017 បន្ទាប់មកម៉ូដែល Cullinan នៅឆ្នាំ 2019 ។ នៅថ្ងៃនេះ ការរចនាបែប Post Opulent ថ្មី នឹងមាននៅលើសែស្រឡាយ Black Badge ។ ធ្វើឲ្យរថយន្ត Black Badge Ghost ជារថយន្តដែលបរិសុទ្ធបំផុត និងមានបច្ចេកវិទ្យាទំនើបបំផុត ក្នុងចំណោមសែស្រឡាយ Black Badge ។

### ការរចនាបែបខ្មៅងងឹត តាម **Post Opulence**

រថយន្ត Ghost ប្រភេទថ្មីនេះ ត្រូវបានបង្កើតឡើងដើម្បីជាការឆ្លើយតបទៅនឹងក្រុមអតិថិជន ដែលចង់បានរថយន្ត Rolls-Royce ដែលរហ័សរហួន មិនសំញ៉ែង មានការផ្សារភ្ជាប់ទៅពិភពខាងក្រៅ ហើយពុំមានការរចនាលើសលុបខ្លាំងពេក ។ រថយន្ត Ghost ថ្មីនេះ មិនត្រឹមតែជារថយន្ត Rolls-Royce ដែលមានបច្ចេកវិទ្យាទំនើបបំផុតនោះទេ ប៉ុន្តែ ក៏មានសោភ័ណភាពបរិសុទ្ធជាងគេបំផុតផងដែរ ។ ក្នុងរយៈពេល 12 ខែចាប់តាំងពីរថយន្តនេះត្រូវបានដាក់ឲ្យមានការបញ្ជាទិញ វាបានក្លាយជាផលិតផលដែលបានលក់ដាច់លឿនជាងគេបំផុតមួយនៅក្នុងប្រវត្តិកាលរបស់ក្រុមហ៊ុន ដោយក្នុងនោះទទួលបានការបញ្ជាទិញចំនួន 3,500 គ្រឿង ទូទាំងពិភពលោក ។

រថយន្តនេះ ក៏ចាប់ផ្តើមប្រើប្រាស់វិធីសាស្រ្តរចនាបែបថ្មី ដោយប្រើប្រាស់វិធីសាស្ត្របែប Minimalism (តិច) និងមានភាពបរិសុទ្ធ។ អ្នករចនាម៉ូដរបស់ Rolls-Royce បានដាក់ឈ្មោះវិធីសាស្ត្រនេះថា “Post Opulence” ហើយការរចនាសោភ័ណភាពរបស់រថយន្តនេះ គឺជាការកាត់បន្ថយការរចនាកុំឲ្យច្រើនពេក និងផ្តោតលើចំណុចសំខាន់ៗ ។ ដើម្បីធ្វើដូច្នេះបាន សម្ភារៈល្អៗឥតខ្ចោះ ត្រូវបានជ្រើសរើសយកមកប្រើប្រាស់ ខណៈដែលការរចនា គឺមានចំនួនកំណត់ មានភាពវៃឆ្លាត និងមិនលេចចេញមកច្បាស់ឡើយ។

ទោះជាយ៉ាងណា សម្រាប់អតិថិជនក្រុមនេះ ដែលចូលចិត្តការរចនាបែប minimalism (តិច) និងវត្ថុល្អៗ គំនិតបដិវដ្តន៍ប្លែក គឺព្យាយាមបង្កើតជារថយន្ត Ghost បែបផ្សេង ដោយការប្រើពណ៌ខាងក្រៅ ដែលបរិសុទ្ធ ហើយការចាត់ថ្នាក់ពណ៌របស់វានៅតែត្រូវបានលើកយកមកពិភាក្សាដដែល ពោលគឺ៖ ពណ៌ខ្មៅ ។ រថយន្ត Black Badge Ghost ឆ្លុះបញ្ចាំងឲ្យឃើញបំណងចង់បានបែបនេះពីអតិថិចន ។ ពោលគឺការរចនាបែប Post Opulence ខ្មៅងងឹត៖ គឺ Minimalism *in extremis* ។

ផ្នែខាងក្រៅ



The Drive, Westhampnett, Chichester, PO18 0SH, UK +44 (0)1243 384000 enquiries@rolls-roycemotorcars.com www.rolls-roycemotorcars.com

Rolls-Royce Motor Cars Limited. Registered in England and Wales. Company number 3522604. Registered address: Summit ONE, Summit Avenue, Farnborough, Hampshire, GU14 0FB.
Rolls-Royce Motor Cars Ltd is authorised and regulated by the Financial Conduct Authority in relation to its credit broking activities in the UK

អតិថិជនមានសេរីភាពក្នុងការជ្រើសរើសយកពណ៌ខាងក្រៅណាមួយក៏បានក្នុងចំណោមពណ៌ទាំង 44,000 ប្រភេទរបស់ Rolls-Royce ដើម្បីបង្កើតបានជាពណ៌បែប Bespoke ពិសេសប្លែក ។ ទោះជាយ៉ាងណា សុភាពបុរស និងសុភាពនារីភាគច្រើនបំផុតដែលស្នើចង់បានរថយន្ត Ghost ដែលមានពណ៌ខ្មៅងងឹត គឺបានជ្រើសរើសយកពណ៌ខ្មៅ ។ ដើម្បីបង្កើតរថយន្តដែលមានពណ៌ខ្មៅងងឹតជាងគេបំផុត ក្នុងឧស្សាហកម្មយានយន្ត ដូច្នេះ ថ្នាំពណ៌ទម្ងន់ 100 ផោន (45 គីឡូក្រាម) ត្រូវបានបំបែកជាអាតូម ហើយត្រូវបានយកទៅបាញ់លើតួដែលមានផ្ទៃពណ៌ស តាមវិធីអេឡិចត្រូស្តាទិច មុនពេលសម្ងួត ។ បន្ទាប់មក រថយន្តនេះត្រូវបានបាញ់ថ្នាំថ្លាពីរស្រទាប់ទៀត មុនពេលយកមកប៉ូលាដោយដៃ ដោយក្រុមការងារចំនួនបួនរូប ដើម្បីធ្វើឲ្យផ្ទៃសម្រេចមានពណ៌រលោងដោយព្យាណូ សម្រាប់ម៉ាកយីហោរថយន្ត Rolls-Royce ។

ដោយប្រើពេលចន្លោះពីបី ទៅប្រាំម៉ោង ប្រតិបត្តិការនេះ មិនត្រូវបានគេស្គាល់ឡើយនៅក្នុងផលិតកម្មបែបបរិមាណ ដោយប្រតិបត្តិការនេះបង្កើតបានជាភាពជាប់មាំ ដែលមិនអាចសម្រេចបានក្រៅពីនេះឡើយ សម្រាប់ឧស្សាហកម្មយានយន្ត។ ជម្រៅនៃភាពខ្មៅងងឹតនេះហើយ ដែលបានក្លាយជាពណ៌ដ៏ល្អឥតខ្ចោះសម្រាប់អតិថិជន ក្នុងការបន្ថែមភ្លឺឆ្នូតដែលឆ្លុះពណ៌គ្នាគូដោយដៃ ដែលធ្វើឲ្យរថយន្ត Black Badge មានសោភ័ណភាព “ខ្មៅ និងពន្លឺណែអុង” ដែលជាសោភ័ណភាពសម្គាល់ឲ្យសែស្រឡាយនៃរថយន្ត Rolls-Royce មួយនេះ។

ដើម្បីធ្វើកិច្ចការដ៏វិសេសវិសាលនេះ ក្រុមអ្នករចនាម៉ូត វិស្វករ និងសិប្បករបែប Bespoke បានសហការគ្នា ដើម្បីបង្កើតដំណើរការមួយដែលអាចកែច្នៃបាន ហើយអនុញ្ញាតឲ្យវត្ថុសម្គាល់នានារបស់ Rolls-Royce ដូចជាទេវរូប Spirit of Ecstasy និងប៉ាណាមុខ Pantheon ដែលរលោងខ្លាំង អាចមានការកែប្រែបាន ។ ជំនួសឲ្យការបាញ់ថ្នាំលើវត្ថុទាំងនេះ គេបានដាក់ចេញនូវទឹកក្រូមអេឡិចត្រូលីតពិសេស បន្ថែមលើដំណើរការបាញ់ស្រោបក្រូម ដែលត្រូវបានបាញ់រួមគ្នានៅលើផ្ទៃលាតជាដែកថែបគ្មានច្រែះ ដែលធ្វើឲ្យផ្ទៃខាងក្រៅរាងខ្មៅងងឹត ។ កម្រាស់ចុងក្រោយ គឺត្រឹមតែមួយមីក្រូម៉ែត្រប៉ុណ្ណោះ គឺស្មើនឹងមួយភាគមួយរយនៃទទឹងសក់របស់មនុស្ស ។ រាល់វត្ថុទាំងអស់នេះត្រូវបានប៉ូលាដោយដៃ ដើម្បីធ្វើឲ្យផ្ទៃក្រូមភ្លឺថ្លាដូចកញ្ចក់ មុនពេលយកទៅបំពាក់លើរថយន្ត ។

ការរៀបចំគ្រឿងបំពាក់ផ្នែកខាងក្រៅរួមមាន កង់កាបោនបែប Bespoke ទំហំ 21 អ៊ិញ ។ ខ្នងកង់នីមួយៗត្រូវបានរចនាម៉ូតសម្រាប់រថយន្ត Blakck Badge Ghost ហើយ ត្រូវបានបង្កើតឡើងដោយបាច់សសៃកាបោន ចំនួន 22 ស្រទាប់ ដែលតម្រៀបលើអក្សចំនួនបី ហើយបត់ជាន់លើគ្នាត្រលប់មកវិញ មករកគែមខាងក្រៅរបស់ខ្នង  ដោយបង្កើតបានជាសរសៃកាបោនសរុប 44 ស្រទាប់ ដែលធ្វើឲ្យកាន់តែជាប់មាំរឹតតែខ្លាំង ។ ដុំកណ្តាលអាលុយមីញ៉ូមបែប 3D ត្រូវបានភ្ជាប់ជាមួយនឹងខ្នង ដោយប្រើប្រាស់ខ្មៅទីតាញ៉ូមសម្រាប់យានអវកាស ហើយមានបំពាក់ជាមួយនឹងគំរបដុំមិនវិល ដែលជាវត្ថុសម្គាល់មួយរបស់ម៉ាកយីហោ Rolls-Royce ដើម្បីធានាថា អក្សរ R ភ្លោះ ស្ថិតនៅឈរត្រង់គ្រប់ពេលវេលា ។ ដើម្បីការពារលើសារធាតុនៃឧបករណ៍ និងផ្ទៃខាងក្រៅដ៏ស្រស់ស្អាតនោះ វ៉ែរនីស្តើងៗត្រូវបានបាញ់ ដើម្បីការពារផ្ទៃខាងក្រៅ ប៉ុន្តែនៅតែអនុញ្ញាតឲ្យអតិថិជនអាចសង្កេតឃើញពីលក្ខណៈពិសេសផ្នែកបច្ចេកទេសក្នុងការរៀបចំសរសៃកាបោននៅលើខ្នងកង់ដ៏ពិសេសនេះ ។



The Drive, Westhampnett, Chichester, PO18 0SH, UK  +44 (0)1243 384000  enquiries@rolls-roycemotorcars.com  www.rolls-roycemotorcars.com

Rolls-Royce Motor Cars Limited. Registered in England and Wales. Company number 3522604. Registered address: Summit ONE, Summit Avenue, Farnborough, Hampshire, GU14 0FB.
Rolls-Royce Motor Cars Ltd is authorised and regulated by the Financial Conduct Authority in relation to its credit broking activities in the UK

## ផ្ទៃខាងក្នុង

សម្ភារៈទំនើបប្រណីត ត្រូវបានបង្កើត និងកែច្នៃឡើងដោយប្រុងប្រយ័ត្ន ដើម្បីរំលេចសោភ័ណភាពពិសេសប្លែកនៅផ្ទៃខាងក្នុង។ នៅពេលរំឭកពីគោលបំណងផ្នែកមេកានិចដ៏អស្ចារ្យរបស់ Black Badge Ghost នោះសម្ភារៈដែលប្រើប្រាស់គឺត្រឹមត្រូវទៅតាមទស្សនវិជ្ជានៃការរចនាម៉ូដបែប Post Opulent របស់ម៉ូដែល Ghost គឺជាការរចនាដែលកំណត់ដោយយថាភូតភាព និងសារធាតុប្រើប្រាស់ ជាជាង ការរចនាបែបចំហរច្បាស់ៗ ។ ក្នុងស្មារតីនេះ ការរចនាវិញត្បាញដ៏ស្មុគស្មាញ ដែលមានបញ្ចូលនូវគំរូគ្រាប់ពេជ្រ ដែលបានបង្កើតបានជាសរសៃកាបោន និងសរសៃលោហៈ ត្រូវបានបង្កើតឡើងដោយសិប្បកររបស់ក្រុមហ៊ុន Rolls-Royce ។

បន្ទះឈើជាច្រើនស្រទាប់ ត្រូវបានបិទនៅតាមផ្ទៃវត្ថុសម្ភារៈនានានៅខាងក្នុង ដោយប្រើប្រាស់បន្ទះឈើខ្មៅសម្រាប់ស្រទាប់ដែលនៅខាងលើបំផុត។ ការធ្វើដូច្នេះ បង្កើតបានជាគ្រឹះពណ៌ខ្មៅសម្រាប់ស្រទាប់កាបោនដែលប្រើពីលើនោះទៀត ។ ស្លឹកឈើដែលត្រូវបានត្បាញដោយប្រើប្រាស់កាបោនស្រោបដោយជ័រ ហើយនិងអំបោះស្រោបដោយលោហៈ ដែលត្រូវបានតម្រៀបជាគំរូគ្រាប់ពេជ្រ ត្រូវបានរៀបចំដោយដៃទទេ សម្រាប់បិទលើសម្ភារៈនានាដែលមានភាពស៊ីសង្វាក់គ្នាល្អឥតខ្ចោះ ហើយបង្កើតបានជាទិដ្ឋភាពបែប 3D ថែមទៀតផង។ ដើម្បីទទួលបានបន្ទះឈើដ៏ល្អបែបនេះ រាល់វត្ថុធាតុនីមួយៗត្រូវបានសម្ងួតរយៈពេលមួយម៉ោងក្រោមសីតុណ្ហភាព 100 អង្សាសេ ។ បន្ទាប់មកទៀត ត្រូវបានយកមកបាញ់គ្រាប់ខ្សាច់ដើម្បីឲ្យមានផ្ទៃគ្រើមសម្រាប់ការបាញ់វ៉េរនីប្រាំមួយជាន់ ដែលត្រូវបានខាត់ដោយដៃ និងប៉ូលា មុនពេលបញ្ចូលទៅក្នុងរថយន្តនីមួយៗ។

ប្រសិនបើមានការបញ្ជាក់នៅក្នុងការកុម្ម៉ង់របស់អតិថិជន នោះ ផ្នែក “ទឹកធ្លាក់” ដែលប្រើសារធាតុកាបោន ស្ថិតនៅផ្នែកកៅអីខាងក្រោយនីមួយៗ នឹងទទួលបាននូវរូបលម្អសម្រាប់សៃស្រឡាយរថយន្ត Black Badge ពោលគឺជានិមិត្តសញ្ញាគណិតវិទ្យាដែលតំណាងឲ្យអានន្ត ។ ដោយត្រូវបានឆ្លាក់ជាបន្ទះអាលុយមីញ៉ូម ប្រើក្នុងវិស័យអវកាស ដែលស្ថិតនៅលើគំរបទូទឹកកកសម្រាប់ស្រាសាំប៉ាញ នៃរថយន្ត Black Badge Ghost សញ្ញានេះត្រូវបានឆ្លាក់នៅចន្លោះស្រទាប់ទីបី និងទីបួន នៃស្រទាប់វ៉េរនី ដែលមានរហូតដល់ទៅ 6 ជាន់ ដោយបង្កើតបានជារូបបញ្ឆោតថា រូបសញ្ញានោះកំពុងអណ្តែតពីលើបន្ទះកាបោន ដូច្នោះដែរ។ អ្នកពូកែផ្នែករចនាសោភ័ណភាព ដែលស្ថិតក្នុងក្រុមរចនាម៉ូដរបស់ Rolls-Royce បានសម្រេចធ្វើឲ្យសោភ័ណភាពរបស់ Black Badge Ghost កាន់តែលេចធ្លោថែមទៀត តាមរយៈការផ្តោតលើការងារប៉ូលាឲ្យភ្លឺ។ ព្រឹលម៉ាស៊ីនត្រជាក់នៅលើតាប្លូ និងនៅផ្នែកខាងក្រោយ ត្រូវបានធ្វើឲ្យទៅជាក្រម៉ៅ ដោយប្រើប្រាស់កំណកចំហាយរូបសាស្ត្រ ដែលនេះជាវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រតិចតួចក្នុងការលាបពណ៌លើលោហៈ ដែលធានាថា វត្ថុទាំងនោះមិនហើរពណ៌ ឬខូចពណ៌ នៅពេលទុកយូរ ឬប្រើប្រាស់ញឹកញាប់។ គោលការណ៍នៃការរចនាបែប Post Opulent ដែលផ្តោតលើសមញ្ញភាព ក៏ត្រូវបានអនុវត្តលើវិនាដកម្មនានានៃការរចនានាឡិកាសម្រាប់រថយន្ត Black Badge Ghost៖ មានតែចុងទ្រនិច ចំណុចលេខ 12, 3, 6 និង 9 ប៉ុណ្ណោះ



Rolls-Royce Motor Cars Limited. Registered in England and Wales. Company number 3522604. Registered address: Summit ONE, Summit Avenue, Farnborough, Hampshire, GU14 0FB.
Rolls-Royce Motor Cars Ltd is authorised and regulated by the Financial Conduct Authority in relation to its credit broking activities in the UK

ដែលត្រូវបានរំលេច ដោយប្រើប្រាស់សារធាតុក្រូម ដែលការរចនានេះធ្វើឲ្យនាឡិកា Black Badge មានសោភ័ណភាពលេចធ្លោបំផុត ។

នាឡិកានេះត្រូវបានអមទៅដោយវត្ថុបង្កើតថ្មីបែប Bespoke ដំបូងគេក្នុងលោក ហើយត្រូវបានបំពាក់លើរថយន្ត Ghost៖ ពោលគឺ ផ្ទៃតាប្លូភ្លឺ ដែលមានបង្ហាញរូបអនន្តដែលភ្លឺចិញ្ចាច ហ៊ុំព័ទ្ធទៅដោយតារាជាង 850 ។ កញ្ចុំផ្កាយ និងរូបសញ្ញានេះ ស្ថិតនៅកៅអីខាងមុខសម្រាប់អ្នកជិះ ហើយកញ្ចុំផ្កាយនេះមិនអាចមិនឃើញទាំងស្រុង នៅពេលដែលអំពូលខាងក្នុងមិនត្រូវបានបើកឲ្យដំណើរការ ។ នៅក្នុងរថយន្ត Ghost រូបសញ្ញា អាននន្តនេះ ត្រូវបានបំភ្លឺដោយអំពូល LED ចំនួន 152 គ្រាប់ ដែលត្រូវបានបិទពីខាងលើ និងពីក្រោមផ្ទៃតាប្លូ  ដែលផ្ទៃតាប្លូនីមួយៗត្រូវបានសម្រិតសម្រាំងឲ្យស៊ីពណ៌គ្នាជាមួយនឹងនាឡិកា និងពន្លឺរបស់ប៊ូតុងបញ្ជានានា។ ដើម្បីធានាថា សញ្ញាអាននន្តមានពន្លឺស្មើ បាន ដូច្នេះ ខ្សែអំពូលកម្រាស់ 2mm ត្រូវបានយកមកប្រើ ដែលមានចំណុចអុចៗ ជាង 90,000 ចំណុចកាត់ដោយកាំរស្មីឡាស៊ែ នៅលើផ្ទៃរូបសញ្ញានោះ ។ ខ្សែអំពូលនេះ មិនត្រឹមតែបំបែកពន្លឺឲ្យភ្លឺស្មើគ្នាប៉ុណ្ណោះទេ ប៉ុន្តែក៏បានជួយបង្កើតពន្លឺព្រិចៗ នៅពេលដែលយើងចោលភ្នែកសំឡឹងទៅលើផ្ទៃតាប្លូនោះ ដែលធ្វើឲ្យនឹកឃើញដល់ចំណាំងពន្លឺរបស់ដំបូលផ្កាយដែលមានទេពស្សុត ។

វិស្វកម្ម

សែស្រឡាយរថយន្ត Black Badge មិនមែនផ្តោតតែលើសោភ័ណភាពប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តោតលើបទពិសោធន៍សម្រាប់ការប្រើប្រាស់ផងដែរ។ អតិថិជនដែលកុម្ម៉ង់រថយន្តនេះ បានទាមទារ រាល់ការបំពាក់គ្រឿង Bespoke សម្រាប់ Black Badge Ghost ត្រូវធ្វើឡើងរាប់ចាប់តាំងពីកន្លែងរចនាម៉ូត រហូតដល់ផ្នែកវិស្វកម្ម របស់ម៉ាកយីហោនេះ។ ដើម្បីធ្វើដូច្នេះបាន ក្រុមអ្នករចនាម៉ូត វិស្វករ និងសិប្បករផ្នែក Bespoke បានសហការគ្នាដើម្បីបង្កើតរថយន្តដែលអាចបើកបរបានមុតមាំ ដែលស៊ីសង្វាក់គ្នាជាមួយនឹងរូបរាងរបស់ Black Badge Ghost ដោយគិតគូរយ៉ាងខ្លាំងលើលក្ខណៈសម្បត្តិនៃការបើកបរដោយឥតខំប្រឹង និងសំឡេងបែបអាគូស្ទិក។

គន្លឹះដែលជួយឲ្យរថយន្តនេះហាក់មានអំណាចគឺ ស្ថាបត្យកម្មនៃភាពប្រណីត ពោលគឺគ្រោងតួរថយន្តអាលុយមីញ៉ូម របស់ Rolls-Royce ដែលធ្លាប់បានប្រើដំបូងគេលើរថយន្តម៉ូដែល Phantom។ គ្រោងនេះមិនត្រឹមតែជួយឲ្យតួរថយន្តមានភាពជាប់មាំយ៉ាងពិសេសប៉ុណ្ណោះទេ ប៉ុន្តែ ក៏បានផ្តល់ភាពអាចបត់បែនបាន និងអាចវាស់ក្រិតបាន ដែលអនុញ្ញាតឲ្យម៉ូដែល Ghost អាចបំពាក់ប្រព័ន្ធរង្វិលកង់បួន ប្រព័ន្ធចង្កូតបួនកង់ទាំងបួន និងប្រព័ន្ធបូម Planar Suspension ដែលជាប្រព័ន្ធទទួលបានពានរង្វាន់ថែមទៀតផង។ សម្រាប់រថយន្ត Black Badge លក្ខណៈសម្បត្តិវិស្វកម្មដ៏ល្អឥតខ្ចោះនេះ ត្រូវបានយកមករចនាឡើងវិញរាប់បញ្ចូលទាំងការបញ្ចូលបូមខ្យល់ដែលមានចំណុះច្រើនជាងមុន ដើម្បីជួយកាត់បន្ថយកុំឲ្យតួឃ្លោងជាងមុន នៅពេលបត់ខ្លាំង។

សមត្ថភាពរបស់ ម៉ាស៊ីន 6.75 លីត្រ V12 បែបទែរបូភ្លោះ របស់ Rolls-Royce ត្រូវបានចាត់ទុកថាគ្រប់គ្រាន់។ ប៉ុន្តែភាពអាចបត់បែនបាននៃរោងចក្រម៉ាស៊ីនបានជួយបង្កើនកម្លាំងថាមពលបន្ថែមចំនួន 29PS ដោយជួយឲ្យទិន្នផលថាមពលកើនឡើងដល់ល

600PS/592hp ។ ប្រព័ន្ធលេខ ត្រូវបានបង្កើនបន្ថែមរង្វិលជុំម៉ាស៊ីនរហូតដល់ទៅ 50NM ពោលគឺកើនឡើងសរុប 900NM ។ ប្រព័ន្ធកម្លាំង (Powertrain) ក៏មានបំពាក់ប្រអប់លេខបែប Bespoke និងការកែសម្រួលលើកបេន ដើម្បីជួយបន្ថែមកម្លាំងថាមពលរបស់ម៉ាស៊ីន។ ប្រអប់លេខ ZF មានប្រាំបីលេខ និងភ្លៅចង្កូតដែលប្ដូងបានទាំងមុខទាំងក្រោយ ធ្វើការយ៉ាងស៊ីសង្វាក់គ្នា ដើម្បីសម្របទៅតាមការកំណត់របស់អ្នកបើកបរ ដោយអាស្រ័យលើធាតុចូលនៃការបត់ប្ដូងចង្កូត និងការជាន់ហ្គែរ។

ដូចគ្នាទៅនឹងគ្រប់ផលិតផលរថយន្តទាំងអស់ក្នុងសៃស្រឡាយ Black Badge របស់រថយន្ត Rolls-Royce ដែរ ប៊ូតុង “Low” ដែលស្ថិតនៅកន្លែងជ្រើសរើសលេខ នឹងបង្ហាញនូវសំណុំបច្ចេកវិទ្យាពេញលេញរបស់ Black Badge Ghost ។ គេអាចសម្គាល់ឃើញតាមរយៈការកែសម្រួលទៅលើម៉ាស៊ីនរបស់រថយន្ត តាមរយៈប្រព័ន្ធស៊ីម៉ាំងថ្មីទាំងស្រុង ដែលបញ្ចេញឲ្យដឹងពីអំណាចថាមពលរបស់រថយន្តនោះ ។ ប្រព័ន្ធរង្វិលជុំម៉ាស៊ីនរហូតដល់ទៅ 900NM នឹងបញ្ចេញឲ្យអស់តាមរយៈកម្លាំអ 1700rpm នៅពេលធ្វើដំណើរដោយប្រើ Low Mode ហើយល្បឿននៃការប្ដូរលេខ នឹងត្រូវបានបង្កើនរហូតដល់ទៅ 50% នៅពេលដែលកបេនត្រូវបានសង្កត់រហូតដល់ 90% ដែលជួយឲ្យ Black Badge Ghost មានថាមពលបម្រុងគ្រប់គ្រាន់ នៅពេលត្រូវការបើកបរក្នុងភាពបន្ទាន់។

ដើម្បីបង្កើនទំនុកចិត្ត នៅពេលប្រើប្រាស់ Black Badge Ghost កន្លែងជាន់ហ្វ្រាំងត្រូវបានលើកឲ្យខ្ពស់ជាងមុន ហើយជាន់ឆាប់ស៊ីជាងមុន ។ រថយន្ត Ghost ដែលមិនមែន Black Badge មានបំពាក់ទៅដោយប្រព័ន្ធហ្វ្រាំងរឹងមាំ ដែលត្រូវបានចាត់ទុកថាល្អលើសពីគ្រប់គ្រាន់រួចទៅហើយ ទោះបីត្រូវជាន់ក្រោមស្ថានភាពមិនអំណោយផលក្ដី និងគ្រប់គ្រាន់សម្រាប់ Black Badge ដែលទិន្នផលថាមពលខ្ពស់ជាងមុនក្ដី ។ ទោះជាយ៉ាងណា ពណ៌ថ្នាំកាប៉ែនហ្វ្រាំងដែលទប់កម្ដៅបានខ្ពស់ ប្រភេទថ្មី ត្រូវបានបង្កើតឡើង ដើម្បីត្រៀមសម្រាប់ការបញ្ជាទិញ រថយន្ត Black Badge Ghost នាពេលខាងមុខ ។

រថយន្ត Black Badge Ghost ចាប់ផ្ដើមទទួលកុម្ម៉ង់ចាប់ពីពេលនេះទៅហើយ។

-ចប់-

ROLLS-ROYCE
MOTOR CARS

The Drive, Westhampnett, Chichester, PO18 0SH, UK +44 (0)1243 384000 enquiries@rolls-roycemotorcars.com www.rolls-roycemotorcars.com

Rolls-Royce Motor Cars Limited. Registered in England and Wales. Company number 3522604. Registered address: Summit ONE, Summit Avenue, Farnborough, Hampshire, GU14 0FB.
Rolls-Royce Motor Cars Ltd is authorised and regulated by the Financial Conduct Authority in relation to its credit broking activities in the UK





## Dimensions

| | |
|---|---|
| Vehicle length | 5546 mm / 218.3 in |
| Vehicle width | 2148 mm / 84.6 in |
| Vehicle height | 1571 mm / 61.9 in |
| Wheelbase | 3295 mm / 129.7in |
| Turning circle | 13 m / 42.7 ft |
| Boot volume (DIN) | 500 ltr |

## Engine

| | |
|---|---|
| Engine / cylinders/ value | V/ 12 / 48 |
| Fuel management | Direct Injection |
| Power output @ engine speed | 591 bhp / 441 kW / 600 PS @ 5250-5750 rpm |
| Max torque @ engine speed | 900 Nm / 664 lb ft @ 1700-4250 rpm |
| Fuel type | 10:1 / Premium Unleaded *1 |

## Weight

| | |
|---|---|
| Unladen weight (DIN) | 2490 kg / 5489.5 lbs |

## Performance

| | |
|---|---|
| Top speed | 250 km/h / 155 mph (governed) |
| Acceleration 0-60 mph | 4.5 seconds |
| Acceleration 0-100 km/h | 4.7 seconds |

## Fuel consumption and CO2 emissions NEDC corr figures*

| | |
|---|---|
| Consumption (combined) | N/A |
| CO2 Emissions (combined) | N/A |

## WLTP figures*

| | |
|---|---|
| Combined consumption | 15.8 ltr /100km / 17.9 mpg |
| CO2 emissions combined | 359 g/km |

*Preliminary data not yet confirmed, subject to change.

ROLLS-ROYCE
MOTOR CARS

The Drive, Westhampnett, Chichester, PO18 0SH, UK +44 (0)1243 384000 enquiries@rolls-roycemotorcars.com www.rolls-roycemotorcars.com

Rolls-Royce Motor Cars Limited. Registered in England and Wales. Company number 3522604. Registered address: Summit ONE, Summit Avenue, Farnborough, Hampshire, GU14 0FB.
Rolls-Royce Motor Cars Ltd is authorised and regulated by the Financial Conduct Authority in relation to its credit broking activities in the UK

លក្ខណៈបច្ចេកទេស

Black Badge Wraith៖ NEDCcorr ការបញ្ចេញឧស្ម័នកាបូនិច (រួម)៖ 367 g/km; ការស៊ីប្រេង៖ 17.5 mpg / 16.1 l/100km; WLTP ការបញ្ចេញឧស្ម័នកាបូនិច (រួម)៖ 370-365 g/km; ការស៊ីប្រេង៖17.2-17.4 mpg / 16.4-16.2 l/100km ។

Black Badge Dawn៖ NEDCcorr ការបញ្ចេញឧស្ម័នកាបូនិច (រួម)៖ 371 g/km; ការស៊ីប្រេង៖ 17.3 mpg / 16.3 l/100km; WLTP ការបញ្ចេញឧស្ម័នកាបូនិច (រួម)៖ 382-380 g/km; ការស៊ីប្រេង៖ 16.7-16.9 mpg / 16.9-16.8 l/100km។

Black Badge Cullinan៖ NEDCcorr ការបញ្ចេញឧស្ម័នកាបូនិច (រួម)៖ 341 g/km; ការស៊ីប្រេង៖ 18.8 mpg / 15.0 l/100km WLTP ការបញ្ចេញឧស្ម័នកាបូនិច (រួម)៖ 377-355 g/km; ការស៊ីប្រេង៖ 17.0-18.1 mpg / 16.62-15.6 l/100km ។

Ghost៖ NEDCcorr ការបញ្ចេញឧស្ម័នកាបូនិច (រួម)៖ 343 g/km; ការស៊ីប្រេង៖ 18.8 mpg / 15.0 l/100km ។ WLTP ការបញ្ចេញឧស្ម័នកាបូនិច (រួម)៖ 347-359 g/km; ការស៊ីប្រេង៖ 17.9-18.6 mpg / 15.2-15.8 l/100km។



The Drive, Westhampnett, Chichester, PO18 0SH, UK +44 (0)1243 384000 enquiries@rolls-roycemotorcars.com www.rolls-roycemotorcars.com

Rolls-Royce Motor Cars Limited. Registered in England and Wales. Company number 3522604. Registered address: Summit ONE, Summit Avenue, Farnborough, Hampshire, GU14 0FB.
Rolls-Royce Motor Cars Ltd is authorised and regulated by the Financial Conduct Authority in relation to its credit broking activities in the UK

## ព័ត៌មានបន្ថែម

លោកអ្នកអាចស្វែងរកសេចក្តីប្រកាសព័ត៌មាន ឯកសារព័ត៌មានផ្សេងៗ ក៏ដូចជារូបភាព និងវីដេអូដែលមានគុណភាពច្បាស់ជាច្រើនទៀត នៅលើគេហទំព័រព័ត៌មានរបស់យើងគឺ PressClub។

លោកអ្នកក៏អាចតាមដានព័ត៌មានអំពីម៉ាកយីហោរបស់យើងនៅលើបណ្តាញសង្គម នានាដូចជា៖ LinkedIn; YouTube; Twitter; Instagram; និង Facebook ។

សូមស្វែងរករូបភាពតាមរយៈតំណភ្ជាប់នេះ៖ https://bit.ly/3Et6243

## កំណត់សម្គាល់សម្រាប់និពន្ធនាយក

ក្រុមហ៊ុនរថយន្ត Rolls-Royce គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់សម្ព័ន្ធក្រុមហ៊ុន BMW Group ហើយខុសស្រឡះទាំងស្រុងពីក្រុមហ៊ុន Rolls-Royce plc ដែលជាក្រុមហ៊ុនផលិតម៉ាស៊ីនយន្តហោះ និងប្រព័ន្ធម៉ាស៊ីនជំរុញ។ បច្ចុប្បន្ន មានបុគ្គលិកជំនាញជាមនុស្សប្រុស និងស្រីចំនួនជាង 2,000 នាក់កំពុងបម្រើការនៅការិយាល័យកណ្តាលរបស់ក្រុមហ៊ុនរថយន្ត Rolls-Royce និងនៅរោងចក្រផលិតកម្មនៅឯ Goodwood, West Sussex ដែលជាទីកន្លែងតែមួយគត់ក្នុងពិភពលោក សម្រាប់ផលិតដោយដៃនូវរថយន្តកំពូលប្រណីតរបស់ក្រុមហ៊ុន ។

## ព័ត៌មានទំនាក់ទំនង I តាមតំបន់

| | | |
|---|---|---|
| Michelle Chan | +65 8321 7041 | michelle.chan@rrmcapac.com |
| Sheryl Kezia | +61 435 779 950 | sheryl.kezia@rrmcapac.com |
| Vera Chen | +65 9816 2480 | vera.chen@rrmcapac.com |
| Lim Shen Yee | +60 12 218 9015 | shen.yee@rrmcapac.com |
| Yvonne Brigitte | +62 819 0635 2975 | yvonne.b@rrmcapac.com |
| Chloe Bui | +84 38 7717442 ^ | chloe@rrmcapac.com |
| Chutinun Guna-Tilaka | +66 61 956 2939 | chutinun@imageimpact.co.th |
| Hal Serudin | +65 6838 9675 | hal.serudin@rolls-roycemotorcars.com |
| Helpdesk | +65 9017 6272 * | info@rrmcapac.com |
| | +66 830766196 | |

*WhatsApp / ^Zalo